# ព្រះពុទ្ធ

# ២៦០០ ឆ្នាំ នៃការត្រាស់ដឹង

ពាក្យថា ព្រះពុទ្ធ ដែលយើងគោរពបូជាសព្វថ្ងៃនេះ គឺជាបុគ្គលនាម សំគាល់ដល់យុវក្សត្រម្នាក់ព្រះនាមថាសិទ្ធត្ថៈ មានជីវិតរស់នៅក្នុងប្រទេសឥណ្ឌាបុរាណប្រហែលជា ២៦៣៥ ឆ្នាំមុន ដែលបានបួសនិងស្វែងរកវិមុត្តិធម៌ គឺវិធីដើម្បីរំដោះខ្លួនឱ្យផុតពីទុក្ខ រហូតដល់រកវិធីនោះឃើញ និងធ្វើខ្លួនឱ្យរួចផុតពីទុក្ខបានដោយវិធីនោះ ដោយខ្លួនឯង។ ការណ៍ដែលព្រះសិទ្ធត្ថៈរកឃើញវិធីដើម្បីរំដោះខ្លួនឱ្យផុតពីទុក្ខ ហើយខ្លួនលោកក៏បានរួចផុតពីសេចក្តីទុក្ខនោះ ហៅថា **ការត្រាស់ដឹង** ដែលក្នុងភាសាបាលីហៅថា ពុទ្ធៈ។ ថ្ងៃដែលព្រះអង្គបានត្រាស់ដឹងនោះ ត្រូវនឹងថ្ងៃ១៥កើត ខែពិសាខ មុនពុទ្ធសករាជ ឬមុនព្រះអង្គចូលបរិនិព្វាន ៤៥ឆ្នាំ ។ ព្រះពុទ្ធអង្គ រូបនេះ ទ្រង់ចូលបរិនិព្វាននៅថ្ងៃ១៥កើតខែពិសាខ ក្នុងព្រះជន្ម៨០វស្សា បន្ទាប់ពីបានប្រើប្រាស់ការត្រាស់ដឹងរបស់ព្រះអង្គផ្សព្វផ្សាយ និងបង្រៀនវិធីដោះស្រាយនោះដល់មនុស្សជាច្រើន អស់រយៈពេល៤៥ឆ្នាំ។ ការរាប់ឆ្នាំសករាជរបស់ពុទ្ធសាសនា ក៏បានចាប់ផ្តើមចាប់តាំងពីថ្ងៃ១រោជ ខែពិសាខ បន្ទាប់ពីថ្ងៃដែលព្រះអង្គបរិនិព្វាន ។

នៅក្នុងព.ស. ២៥០០ ប្រទេសកម្ពុជាបានប្រារព្ធនូវពិធីបុណ្យមួយដ៏មហោឡារឹក ដើម្បីអបអរសាទរដល់ការដែលព្រះពុទ្ធសាសនាមានអាយុកាលគ្រប់២៥០០ឆ្នាំ នៅថ្ងៃវិសាខបូជា ព.ស. ២៥០០ ដែលត្រូវនឹងថ្ងៃច័ន្ទ ១៥កើត ខែពិសាខ ឆ្នាំរកា នព្វស័ក ឬទី ១៣ ឧសភា ឆ្នាំ១៩៥៧។ ពេលនោះ ប្រជារាស្ត្រខ្មែរមានការរំភើប រីករាយណាស់ ហើយបាននាំគ្នានិយាយថា «សំណាងណាស់បានកើតទាន់ពាក់កណ្តាលសាសនា»។ ជនមានសទ្ធាជាច្រើនបាននាំគ្នាបួសជាសមណៈពុទ្ធសាសនា ព្រោះមានជំនឿថា បានបុណ្យកុសលច្រើនណាស់។

ឥឡូវនេះ កម្ពុជាយើងនឹងបានជួបនូវព្រឹត្តិការណ៍មួយទៀតដ៏សំខាន់ដូចគ្នាដែរ ឬក៏អាចសំខាន់ជាងព្រឹត្តិការណ៍នាព.ស.២៥០០ ទៀតផងក៏ថាបាន នុ៎ះគឺ ខួបគម្រប់ ២៦០០ឆ្នាំ នៃ**ការបានត្រាស់ដឹងជាព្រះពុទ្ធ** របស់ព្រះសមណគោត្តម! ព្រឹត្តិការណ៍ដ៏សំខាន់នោះ

គឺត្រូវ នឹងថ្ងៃ១៥កើត ខែពិសាខ ព.ស.២៥៥៥ ដោយថ្ងៃនោះ ត្រូវនឹងថ្ងៃអង្គារ ទី១៧ ខែឧសភា ឆ្នាំ២០១១។

**ការត្រាស់ដឹង** គឺជាការសំខាន់ដែលមិនមានអ្វីប្រៀបប្រដូចបាន ព្រោះថាបើមិនមានការត្រាស់ដឹងទេ ក៏មិនមានព្រះពុទ្ធ និងមិនមានពុទ្ធសាសនាដែលខ្មែរយើងគោរពបូជា ហើយដែលរដ្ឋាភិបាលខ្មែរបានគោរពដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញថាជាសាសនារបស់រដ្ឋ។ វិធីរំលត់ទុក្ខ គឺជាលទ្ធផលដែលកើតមកពីការត្រាស់ដឹង ជាផ្លូវដែលនាំទៅរកការរំលត់ទុក្ខ ដែលបុគ្គលណាក៏អាចប្រើនូវវិធីនេះបានដែរ ហើយបើបានយកវិធីនេះមកប្រើឬអនុវត្តដោយត្រឹមត្រូវត្រឹមត្រង់ គ្រប់គ្រាន់ទៅតាមលក្ខណ្ឌនិងតម្រូវការរបស់វិធីរំលត់ទុក្ខនោះហើយ បុគ្គលនោះក៏នឹងអាចបានរួចផុតពីទុក្ខ និងក្លាយខ្លួនទៅជាព្រះពុទ្ធបានដូចជាព្រះសិទ្ធត្ថៈដែរ។

## តើអ្វីទៅជាវិធីសម្រាប់រំលត់ទុក្ខនោះ?

វិធីសម្រាប់រំលត់ទុក្ខរបស់ព្រះពុទ្ធអង្គនេះ ក្នុងភាសាបាលីឬភាសាព្រះពុទ្ធហៅថា **ទុក្ខនិរោធគាមិនីបដិបទា** (អានថា ទុក្ខៈ និរោធៈ គាមិនី ប៉ៈដិប៉ៈទា) ប្រែឱ្យចំមានសេចក្ដីថា ការប្រព្រឹត្តដែលនាំទៅរកការរំលត់អស់នូវសេចក្ដីទុក្ខ។ ទុក្ខនិរោធគាមិនីបដិបទា នេះ ហៅម្យ៉ាងទៀតថា **អដ្ឋង្គិកមគ្គ** ប្រែថា មគ្គ ឬផ្លូវ ឬវិធីដែលប្រកបដោយអង្គ៨ ដែលរួមមាន៖

1. ការមានទស្សនៈត្រូវ សម្មាទិដ្ឋិ
2. ការគិតត្រូវ សម្មាសង្កប្បៈ
3. ការនិយាយត្រូវ សម្មាវាចា
4. ការធ្វើអំពើត្រូវ សម្មាកម្មន្តៈ
5. ការចិញ្ចឹមជីវិតត្រូវ សម្មាអាជីវៈ
6. ការព្យាយាមត្រូវ សម្មាវាយាមៈ
7. ការមានសតិត្រូវ សម្មាសតិ
8. ការធ្វើចិត្តឱ្យនឹងត្រូវ សម្មាសមាធិ

## តើ វិធីសម្រាប់រំលត់ទុក្ខ នេះ អនុវត្តដោយរបៀបណា?

ក្នុងការអនុវត្តអង្គទាំង៨នៃវិធីរំលត់ទុក្ខនេះ អនុវត្តជនត្រូវ៖

1. សិក្សា វិធីដែលប្រកបដោយអង្គ៨នេះ ឱ្យបានយល់ច្បាស់គ្រប់ជ្រុងជ្រោយ ទាំងព្យញ្ជនន័យ និងអត្ថន័យ ដែលបានសម្តែងទុកដោយព្រះសម្មាសម្ពុទ្ធ

2. ជឿជាក់ច្បាស់នៅក្នុងចិត្តថា
   2.1. ជីវិតនេះពិតជាមានសេចក្តីទុក្ខមែន (ទុក្ខអរិយសច្ចៈ)
   2.2. សេចក្តីទុក្ខនេះ សុទ្ធតែកើតឡើងដោយអាស្រ័យហេតុ (ទុក្ខសមុទយអរិយសច្ចៈ)
   2.3. សេចក្តីទុក្ខនេះ អាចរំលត់ឱ្យអស់ទៅបាន (ទុក្ខនិរោធៈ)
   2.4. ជឿច្បាស់ថា មានវិធីដែលអាចកំចាត់ហេតុដែលនាំឱ្យកើតសេចក្តីទុក្ខនោះបាន (ទុក្ខនិរោធគាមិនីបដិបទា)

3. ការអនុវត្តន៍នូវវិធីដែលមានអង្គទាំង៨នេះ ត្រូវមានលក្ខណៈជាមជ្ឈិមាបដិបទា ឬ មធ្យមប្រតិបទ ក្នុងភាសាសំស្ក្រឹត គឺៈ
   3.1. មិនតឹងហួសហេតុពេក (អត្តកិលមថានុយោគ)
   3.2. មិនធូររលុងពេក (កាមសុខល្លិកានុយោគ)
   3.3. ត្រូវមានលក្ខណៈជាមធ្យម ឬ ដែលខ្មែរយើងតែងប្រើពាក្យថា ដើរផ្លូវកណ្តាល

ដូច្នេះ ការប្រារព្ធខួបនៃការត្រាស់ដឹងគម្រប់២៦០០ឆ្នាំនេះ គឺជាការរំលឹកដាស់តឿន និង លើកទឹកចិត្តដើម្បីឱ្យកម្ពុជបុត្រគ្រប់រូប ងាកមករកការដោះស្រាយបញ្ហាជីវិតរបស់ខ្លួន បញ្ហាសង្គម បញ្ហាប្រទេសជាតិ និងបញ្ហាពិភពលោកដោយ

1. វិធីដែលត្រឹមត្រូវ មានហេតុមានផល ប្រកបដោយការសិក្សាច្បាស់លាស់ (សម្មា)
2. ដោយការជឿជាក់លើខ្លួនឯងនិងសក្តានុពលក្នុងឋានៈជាមនុស្ស ជាជាងទៅពឹងលើអំណាចដែលនៅក្រៅខ្លួន មានវត្ថុសក្តិសិទ្ធិ ទេវតា និងអាទិទេពនានា (អរិយៈ)
3. ដោយការអនុវត្តន៍ដែល
   3.1. មិនយកតឹងពេកមិនយកធូរពេក យកតឹងខ្លះយកធូរខ្លះ
   3.2. មិនងាកឆ្វេងពេកមិនងាកស្តាំពេក យកឆ្វេងខ្លះយកស្តាំខ្លះ
   3.3. មិនឈ្នះតែអញមិនឈ្នះតែឯង អញឈ្នះខ្លះឯងឈ្នះខ្លះ
   3.4. មិនចាញ់តែអញមិនចាញ់តែឯង អញចាញ់ខ្លះឯងចាញ់ខ្លះ
   3.5. មិនមានតែអញមិនមានតែឯង អញមានខ្លះឯងមានខ្លះ

3.6. មិនអត់តែអញមិនអត់តែឯង អញអត់ខ្លះឯងអត់ខ្លះ (មជ្ឈិមា)

3.7. ។ល។